**KINGDOM OF CAMBODIA**
**Nation Religion King**
*****

No: ០៧១/២២

# សេចក្តីជូនដំណឹង
# ស្តីពី
# ការឈ្នះពានរង្វាន់អចលនទ្រព្យនៃពានរង្វាន់ធុរកិច្ចអាស៊ានឆ្នាំ ២០២២

**រ៉ូយ៉ាល់ គ្រុប ភ្នំពេញ អេសអ៊ីហ្សិត ម.ក** (**ស្ថិតក្នុងដំណើរការផ្លាស់ប្តូរជាផ្លូវការ**)មានសេចក្តីសោមនស្សរីករាយ និងកិត្តិយស ដែលបានឈ្នះពានរង្វាន់ធុរកិច្ចអាស៊ាន ២០២២ (ABA) ក្នុងប្រភេទពានរង្វាន់វិស័យអាទិភាព ដែលប្រព្រឹត្តទៅជាមួយនឹងកិច្ចប្រជុំកំពូលធុរកិច្ច និងការវិនិយោគអាស៊ានឆ្នាំ ២០២២ នៅថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ២០២២ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។

ពិធីប្រគល់ពានរង្វាន់នេះ ធ្វើឡើងក្រោមអធិបតីភាព **ឯកឧត្តម ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន **អ្នកឧកញ៉ា គិត ម៉េង** ប្រធានក្រុមប្រឹក្សាប្រឹក្សាធុរកិច្ចអាស៊ាន ឆ្នាំ២០២២ និងភ្ញៀវកិត្តិយសក្នុងវិស័យឯកជន និងសាធារណៈ។

លោក Fong Nee Wai ប្រធានផ្នែកហិរញ្ញវត្ថុនៃ PPSP បានឡើងទទួលពានរង្វាន់តំណាងឱ្យក្រុមហ៊ុននៅក្នុងព្រឹត្តិការណ៍នេះ។ PPSP បានឈ្នះពានរង្វាន់ក្នុងចំណោមកត្តាផ្សេងៗទៀត ដោយសារតែការរួមចំណែករបស់ក្រុមហ៊ុនក្នុងសង្គមកម្ពុជា តាមរយៈការផ្តល់ឱកាសការងារ ហេដ្ឋារចនាសម្ព័ន្ធ និងការលើកកំពស់កម្រិតជីវភាពជាដើមដល់ប្រជាជនកម្ពុជា។

ពានរង្វាន់ធុរកិច្ចអាស៊ាន (ABA) គឺជាព្រឹត្តិការណ៍កម្រិតអន្តរជាតិដ៏មានកិត្យានុភាពដែលប្រារព្ធឡើងជារៀងរាល់ឆ្នាំដោយក្រុមប្រឹក្សាប្រឹក្សាធុរកិច្ចអាស៊ាន (ASEAN BAC) ចាប់តាំងពីឆ្នាំ ២០០៧។ ជាមួយនឹងការអនុវត្តរយៈពេល ១៥ ឆ្នាំ ព្រឹត្តិការណ៍ ABA បាននាំមកនូវឱកាសសម្រាប់ធុរកិច្ចដើម្បីបញ្ជាក់ឡើងវិញនូវជំហរ និងកិត្យានុភាពរបស់ពួកគេក្នុងចំណោម ដៃគូឧស្សាហកម្ម ជំរុញការប្រកួតប្រជែង និងសមាហរណកម្មរបស់ពួកគេ និងលើកកំពស់ម៉ាកយីហោទូទាំងតំបន់អាស៊ាន និងក្នុងកម្រិតពិភពលោក។




ភ្នំពេញ, ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០២២
**រ៉ូយ៉ាល់ គ្រុប ភ្នំពេញ អេសអ៊ីហ្សិត ម.ក**
(**ស្ថិតក្នុងដំណើរការផ្លាស់ប្តូរជាផ្លូវការ**)